**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**

លេខ: ០៦០/១៨ សជណ

# សេចក្តីជូនដំណឹង

អនុវត្តតាមប្រសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** រដ្ឋបាលរាជធានីភ្នំពេញ សូមជម្រាបជូនដំណឹងដល់សាធារណជនទាំងអស់ឱ្យបានជ្រាបថា ដើម្បីសម្រួលដល់ការចំណាយក្នុងការធ្វើដំណើររបស់មន្ត្រីរាជការ កងកំលាំងប្រដាប់អាវុធ បងប្អូនប្រជាពលរដ្ឋ កម្មករ កម្មការិនី...ទាំងអស់ នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ និងពីរាជធានីភ្នំពេញ ទៅតាមបណ្តាខេត្ត និងពីបណ្តាខេត្ត មករាជធានីភ្នំពេញវិញ ជួបជុំគ្រួសារប្រកបដោយសេចក្តីសប្បាយរីករាយ ក្នុងឱកាសបុណ្យភ្ជុំបិណ្ឌខាងមុខ រដ្ឋបាលរាជធានីភ្នំពេញ នឹងរៀបចំរថយន្តក្រុងចំនួន២១៥ គ្រឿង សម្រាប់បម្រើសេវាដឹកជញ្ជូនសាធារណៈដោយមិនបង់ប្រាក់ ដូចខាងក្រោម:

១-<u>សម្រាប់ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ</u> រដ្ឋបាលរាជធានីភ្នំពេញ ប្រើប្រាស់រថយន្តក្រុង ៩៥ គ្រឿង រយៈពេល ០៣ថ្ងៃ ពីថ្ងៃទី ០៨ ដល់ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៨ ។

២-<u>សម្រាប់ប្រជាពលរដ្ឋនៅតាមបណ្តាខេត្ត</u> រដ្ឋបាលរាជធានីភ្នំពេញ បានរៀបចំរថយន្តក្រុង ចំនួន ១២០ គ្រឿង សម្រាប់ដឹកជញ្ជូនមន្ត្រីរាជការ កងកំលាំងប្រដាប់អាវុធ ប្រជាពលរដ្ឋ កម្មករ កម្មការិនី...ពីរាជធានីភ្នំពេញ ទៅតាមបណ្តាខេត្ត និងពីបណ្តាខេត្តមករាជធានីភ្នំពេញរយៈពេល ០៦ថ្ងៃ ចាប់ពីថ្ងៃទី០៦ ដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៨ ដោយចេញដំណើរចាប់ពីម៉ោង ៥:៣០ ព្រឹក ។

**ចំពោះទីតាំងចំណតចេញដំណើរទៅតាមបណ្តាខេត្ត រដ្ឋបាលរាជធានីភ្នំពេញ រៀបចំដូចខាងក្រោម៖**

| ល.រ | បរិយាយ | រាជធានី-ខេត្ត | ចំនួនរថយន្ត | រថយន្តសរុប | ចំណតចេញដំណើរ |
|---|---|---|---|---|---|
| ១ | ផ្លូវជាតិលេខ១ | ភ្នំពេញ-ស្វាយរៀង | ០៥ គ្រឿង | ១០ គ្រឿង | ផ្លូវ៦០ម៉ែត្រ ទល់មុខក្រុមហ៊ុនម៉ែកស៊ីដែសបិន |
| | | ភ្នំពេញ-ព្រៃវែង | ០៥ គ្រឿង | | |
| ២ | ផ្លូវជាតិលេខ២ | ភ្នំពេញ-តាកែវ | ០៥ គ្រឿង | ១០ គ្រឿង | ផ្លូវ៦០ម៉ែត្រ ទល់មុខក្រុមហ៊ុនម៉ែកស៊ីដែសបិន |
| | | ភ្នំពេញ-កែប | ០៥ គ្រឿង | | |
| ៣ | ផ្លូវជាតិលេខ៣ | ភ្នំពេញ-កំពត | ១០ គ្រឿង | ១០ គ្រឿង | ចំណតផ្សារសិនជូវថ្លៃហ្វា |
| ៤ | ផ្លូវជាតិលេខ៤ | ភ្នំពេញ-កំពង់ស្ពឺ | ០៣ គ្រឿង | ១០ គ្រឿង | ចំណតផ្សារសិនជូវថ្លៃហ្វា |
| | | ភ្នំពេញ-ព្រះសីហនុ | ០៧ គ្រឿង | | |
| ៥ | ផ្លូវជាតិលេខ៥ | ភ្នំពេញ-កំពង់ឆ្នាំង | ០៥ គ្រឿង | ៤០ គ្រឿង | ចំណតស្ទូនប្បារឬស្សីកែវ |
| | | ភ្នំពេញ-ពោធិ៍សាត់ | ០៥ គ្រឿង | | |
| | | ភ្នំពេញ-បាត់ដំបង | ១៥ គ្រឿង | | |
| | | ភ្នំពេញ-បន្ទាយមានជ័យ | ១៥ គ្រឿង | | |
| ៦ | ផ្លូវជាតិលេខ៦ | ភ្នំពេញ-កំពង់ធំ | ០៥ គ្រឿង | ១៥ គ្រឿង | ផ្លូវបេតុងក្នុងតំបន់អភិវឌ្ឍន៍ជ្រោយចង្វារ ខាងជើងរង្វង់មូលព្រហ្មមុខ ៤ |
| | | ភ្នំពេញ-សៀមរាប | ១០ គ្រឿង | | |

៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

| | | | | | |
|---|---|---|---|---|---|
| ៧ | ផ្លូវជាតិលេខ៦,៧ | ភ្នំពេញ-កំពង់ចាម | ១០ គ្រឿង | ១០ គ្រឿង | ផ្លូវបត់ក្នុងតំបន់អភិវឌ្ឍន៍ព្រែកលៀប ចង្វារ ខាងជើងរង្វង់មូលព្រែកហូមុខ ៤ |
| ៨ | ផ្លូវជាតិលេខ៦,៨ | ភ្នំពេញ-ត្បូងឃ្មុំ | ០៥ គ្រឿង | ១៥ គ្រឿង | ចំណតគីឡូម៉ែត្រលេខ៩ |
| | | ភ្នំពេញ-ក្រចេះ | ០៥ គ្រឿង | | |
| | | ភ្នំពេញ-ស្ទឹងត្រែង | ០៥ គ្រឿង | | |
| **សរុប** | | | | ១២០ គ្រឿង | |

អាស្រ័យហេតុនេះ សូមបងប្អូនមន្ត្រីរាជការ កងកំលាំងប្រដាប់អាវុធ ប្រជាពលរដ្ឋ កម្មករ កម្មការិនី...ទាំងអស់ ជ្រាប និងចូលរួមធ្វើដំណើរតាមរថយន្តក្រុងរបស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) រាជធានីភ្នំពេញ ប្រកបដោយសុវត្ថិភាព និងជាសុភភាព។

ថ្ងៃ ពុធ ៨ រោច ខែ ភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១៨

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

***កន្លែងទទួល៖***

-គ្រប់រដ្ឋបាលខេត្ត
"ដើម្បីចូលរួមសហការ"

-គ្រប់ប្រព័ន្ធផ្សព្វផ្សាយ
"ដើម្បីផ្សព្វផ្សាយ"

- ឯកសារ-កាលប្បវត្តិ